# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ
**របស់**
# សមាគមសហគ្រិនស្ត្រីកម្ពុជា
## CAMBODIA WOMEN ENTREPRENEURS ASSOCIATION

## ជំពូកទី ១
## គោលបំណង និងគោលដៅ

### ប្រការ១ .–
**អំពីគោលបំណង**

**សមាគមសហគ្រិនស្ត្រីកម្ពុជា**មានគោលបំណងសំខាន់គឺ៖

- ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងភាពជាដៃគូដ៏មានសារៈសំខាន់ក្នុងការកសាងប្រទេសជាតិ និងអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជាស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា
- ធ្វើជាតំណាង និងលើកកម្ពស់ទស្សនៈរបស់សមាជិក **សសសក** អំពីកិច្ចការដែលជាផលប្រយោជន៍រួមតាមការស្រាវជ្រាវ
- ទំនាក់ទំនង និងលើកទឹកចិត្តឲ្យមានការសន្ទនា និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិង អន្តរជាតិ ស្ថាប័នរដ្ឋ និងឯកជន និងបណ្តាអង្គការផ្សេងទៀតដើម្បីសម្រួលដល់របរអាជីវកម្ម និងការអភិវឌ្ឍប្រកបដោយ និរន្តរភាពនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា
- ចូលរួមផ្តល់យោបល់ដែលទាក់ទងនឹងអាជីវកម្មរបស់សមាជិកដែលមានដូចជា ព័ត៌មានកម្មវិធីបណ្តុះបណ្តាល និងការលើកកម្ពស់ផលិតផល
- លើកកម្ពស់ចំណេះដឹងដល់សហគ្រិនស្ត្រី និងតួនាទីរបស់ស្ត្រីក្នុងការធ្វើរបរអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- លើកកម្ពស់ស្មារតីភាពជាសហគ្រិន ក្នុងចំណោមសហគ្រិនស្ត្រីកម្ពុជាប្រកបអាជីវកម្ម។

### ប្រការ២ .–
**អំពីគោលដៅ**

សមាគម មានគោលដៅសំខាន់ៗ ក្នុងការផ្តល់ការលើកទឹកចិត្ត និងគាំទ្រដល់ការលូតលាស់របស់អាជីវកម្មដែលស្ត្រីជាកម្មសិទ្ធិករនៅក្នុងប្រទេស តាមរយៈការប្រឹងប្រែងរួមគ្នា ការបង្កើតជាបណ្តាញនិងការកសាងឲ្យមានសំឡេងតែមួយចំពោះភាគីពាក់ព័ន្ធសម្រាប់ផលប្រយោជន៍រួម។

សមាគម មានគោលដៅចូលរួមបង្កើត និងថែរក្សានូវបរិយាកាសស្មិទ្ធិស្មាលក្នុងរបរអាជីវកម្មនិងការគាំទ្រដល់ការប្រកួតប្រជែង នៃរបរអាជីវកម្មដែលស្ត្រីជាកម្មសិទ្ធិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការកំណត់ឈ្មោះទីស្នាក់ការអត្តសញ្ញាណនិងត្រា

### ប្រការ៣ .–
**អំពីការបង្កើត និងការកំណត់ឈ្មោះ**

សមាគមនេះត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់ចែងនៅ ក្នុងជំពូកទី៣មាត្រា៤២ ត្រង់កឋាខណ្ឌទី១ និងស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

សមាគមនេះមានឈ្មោះជាភាសាខ្មែរថា សមាគមសហគ្រិនស្ត្រីកម្ពុជា សរសេរអក្សរកាត់ថា **ស.ស.ស.ក** និងមានឈ្មោះជាភាសាអង់គ្លេសថា CAMBODIA WOMEN ENTREPRENEURS ASSOCIATION សរសេរជាអក្សរកាត់ថា C.W.E.A ។

**ប្រការ៤ ._**

**អំពីការកំណត់ទីស្នាក់ការ**

**សមាគមសហគ្រិនស្ត្រីកម្ពុជា**មានទីស្នាក់ការណ្តាលតាំងនៅរាជធានីភ្នំពេញ។ សមាគមអាចបង្កើតឲ្យមានទីស្នាក់ការសាខារបស់ខ្លួននៅតាមបណ្តាខេត្តនានាទូទាំងព្រះរាជាណាចក្រកម្ពុជា ទៅតាមតម្រូវការចាំបាច់របស់សមាគម។

ទីស្នាក់ការកណ្តាល និងទីស្នាក់ការសាខានៅតាមបណ្តាខេត្តនានា អាចត្រូវផ្លាស់ប្តូរបាននៅក្នុងករណីចាំបាច់ ដោយត្រូវអនុវត្តទៅតាមសេចក្តីសម្រេចចិត្តក្នុងសំឡេង ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

**ប្រការ៥ ._**

**អំពីការកំណត់អត្តសញ្ញាណ**

**សមាគមសហគ្រិនស្ត្រីកម្ពុជា** គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃ មិនប្រកាន់ពូជសាសន៍មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ដោយមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្សឲ្យទៅចូលរួមនៅក្នុងសកម្មភាពទាំងឡាយណាដែលគាំទ្រដល់ គណបក្សនយោយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។

**សមាគមសហគ្រិនស្ត្រីកម្ពុជា** គឺជាសមាគមដែលបម្រើឲ្យសមាជិករបស់ខ្លួនតែប៉ុណ្ណោះ។

**ប្រការ៦._**

**អំពីការកំណត់សញ្ញាសម្គាល់ និងត្រា**

**សមាគមសហគ្រិនស្ត្រីកម្ពុជា** មានសញ្ញាសម្គាល់ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយលក្ខន្តិកៈនេះ។ ត្រារបស់សមាគមមានសណ្ឋានជារង្វង់មូលក្នុងទំហំ ៣៤ ម.ម ដោយមានសញ្ញាសម្គាល់នៅពីខាងក្នុងរង្វង់មូល និងកំណត់ប្រើនូវប្រភេទទឹកត្រាពណ៌ខៀវ។

## ជំពូកទី៣
## សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

**ប្រការ៧ ._**

**អំពីសមាជិកភាព**

ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅដែលមានអាជីវកម្មផ្ទាល់ខ្លួន ឬជាថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនណាមួយមានសិទ្ធិសុំចូលជាសមាជិករបស់សមាគមបាន។ រាល់សមាជិករបស់សមាគមទាំងអស់ត្រូវគោរព និងអនុវត្តទៅតាមច្បាប់នានា លិខិតបទដ្ឋានគតិយុត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងរាល់សេចក្តីសម្រេចរបស់សមាគម។

**ប្រការ៨ ._**

**អំពីសមាជិករបស់សមាគម**

សមាជិករបស់**សមាគមសហគ្រិនស្ត្រីកម្ពុជា** រួមមានៈ

១ - សមាជិកស្ថាបនិក គឺជាអ្នកដែលបានផ្តួចផ្តើមបង្កើតសមាគមនេះឡើង

២ - សមាជិកកិត្តិយស គឺជាអ្នកសិក្សាជាន់ខ្ពស់ ជាអ្នកការទូតរបស់ព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយ ដែលបានរួមវិភាគទានដល់ការអភិវឌ្ឍស្ត្រីក្នុងរបរអាជីវកម្ម និងជាអ្នកដែលបានចូលរួចផ្តល់ជាគំនិតយោបល់ជួយជ្រោមជ្រែងដល់សមាគមនេះដើម្បីបានបង្កើត និងដំណើរការដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន

៣ - សមាជិកសកម្ម គឺជាអ្នកចូលរួមអនុវត្តក្នុងសកម្មភាពរបស់សមាគមក្នុងនោះមានដូចជាការពិភាក្សាផ្តល់នូវបទពិសោធន៍អាល់កិច្ចការ និងសំណូមពរផ្សេងៗ របស់សមាគម

៤- សមាជិកគាំទ្រ គឺជាអ្នកដែលផ្តល់នូវប្រភពធនធានមានដូចជា សម្ភារ ថវិកា និងស្មារតីនៃការគាំទ្រឲ្យសមាគមមានដំណើរការស្របតាមគោលបំណងរបស់ខ្លួន។

**ប្រការ៩ ._**

**អំពីការជ្រើសរើសបុគ្គលិក**

សមាគមអាចជ្រើសរើសបុគ្គលិកឲ្យចូលបម្រើការងារទៅតាមការចាំបាច់របស់សមាគម នឹងត្រូវអនុវត្តតាមរយៈការប្រឡង ឬការធ្វើតេស្ត និងត្រូវចុះកិច្ចសន្យាការងារដោយអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១០ ._**

**អំពីតួនាទី ភារកិច្ចរបស់សមាជិក និងបុគ្គលិក**

គ្រប់សមាជិក និងបុគ្គលិករបស់សមាគម ត្រូវបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន ទៅតាមការកំណត់ដូចមានចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគម។

គ្រប់សមាជិកនិងបុគ្គលិករបស់សមាគម មិនត្រូវបានអនុញ្ញាតឲ្យយកឈ្មោះរបស់សមាគមទៅបម្រើនៅក្នុងផលប្រយោជន៍បុគ្គល ឬបម្រើឲ្យផលប្រយោជន៍គណបក្សនយោបាយណាមួយឡើយ។

**ប្រការ១១ ._**

**អំពីការបាត់បង់សមាជិកភាព**

ចំពោះការបាត់បង់សមាជិកភាពរបស់សមាគម ត្រូវបានកំណត់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ទទួលមរណភាព
- បានដាក់ពាក្យសុំលាឈប់ដោយផ្ទាល់ជាលាយលក្ខណ៍អក្សរ ដោយត្រូវដាក់ជូនទៅក្រុមប្រឹក្សាភិបាលឲ្យបាន ១៥ ថ្ងៃ ( ដប់ប្រាំថ្ងៃ ) មុននឹងលាឈប់ពីការងារ
- ត្រូវបានបណ្តេញចេញដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលតាមសំឡេង ២/៣ (ពីរភាគបី)នៃសមាជិកក្រុមប្រឹក្សាភិបាល ក្រោយពីទទួលបានការណែនាំពីប្រធានសមាគមចំនួន ២(ពីរ)លើករួចមកហើយនៅតែពុំកែខ្លួនដោយមូលហេតុមិនគោរពទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគម
- មានជាប់ពិរុទ្ធក្នុងបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលមានសាលក្រម ឬសាលដីកាស្ថាពរដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា
- មានជំងឺវិបល្លាសស្មារតី ឬវិកលចរិត ដែលមានលិខិតបញ្ជាក់ចេញដោយមន្ទីរពេទ្យស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១២ ._**

**អំពីការបញ្ឈប់**

ក្នុងករណីការបញ្ឈប់សមាជិកណាមួយរបស់សមាគមនោះ ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំគ្នាដើម្បីសម្រេច។

## ជំពូកទី៤
## រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ១៣ ._**

**អំពីរចនាសម្ព័ន្ធ**

**សមាគមសហគ្រិនស្ត្រីកម្ពុជា**មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖

- សន្និបាត គឺជាស្ថាប័នដឹកនាំកំពូលរបស់សមាគម សន្និបាតរួមមាន សន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ
- ក្រុមប្រឹក្សាភិបាល

**ប្រការ១៤ ._**

**អំពីសន្និបាតសាមញ្ញ**

សន្និបាតសាមញ្ញ ត្រូវបានកំណត់រៀបចំឡើងនៅរៀងរាល់មួយឆ្នាំម្តង ដោយមានការចូលរួមពីសមាជិកទាំងអស់របស់សមាគមតាមការអញ្ជើញរបស់ប្រធានសមាគម។សមាជិកកិត្តិយសមានសិទ្ធិចូលរួមក្នុងអង្គសន្និបាតបានប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ រីឯនីតិវិធី របៀបវារៈ ទីកន្លែងនិងពេលវេលាជាភារកិច្ចរបស់រដ្ឋបាល។

**អំពីភារកិច្ចរបស់សន្និបាតសាមញ្ញ រួមមាន**

- បោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាភិបាល នៅពេលចប់អាណត្តិ
- ពិនិត្យ វាយតម្លៃលើរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុវត្តកន្លងមក
- ពិនិត្យនិងអនុម័តលើទិសដៅ គោលបំណង និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងឬលក្ខខណ្ឌការងារ
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលស្នើឡើងដោយ ក្រុមប្រឹក្សាភិបាល។

## ប្រការ១៥ ._

**អំពីសន្និបាតវិសាមញ្ញ**

ក្នុងករណីចាំបាច់ ឬពិសេស សមាគមអាចរៀបចំសន្និបាតវិសាមញ្ញបានដោយមិនកំណត់ពេលវេលាតាមការអញ្ជើញ របស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣(ពីភាគបី) នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាលរបស់សមាគម។

**អំពីភារកិច្ចរបស់សន្និបាតវិសាមញ្ញ រួមមាន**

- ពិនិត្យ ពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈក្នុងករណីចាំបាច់
- ពិនិត្យ សម្រេចលើការផ្លាស់ប្តូរប្រធានសមាគម
- ពិនិត្យនិងអនុម័តលើការរំលាយសមាគមនិងការចាត់ចែងទ្រព្យសម្បត្តិរបស់សមាគម
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលចាំបាច់នៅក្នុងសមាគម។

## ប្រការ១៦ ._

**អំពីក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល មានសមាជិកយ៉ាងតិច ៥(ប្រាំ)រូប និងមានអាណត្តិ ៣(បី) ឆ្នាំ។ នៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកក្រុមប្រឹក្សាភិបាលចាស់មានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជាថ្មីទៀតបាន។

## ប្រការ១៧ ._

**អំពីសមាជិកក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសំឡេងគាំទ្រ ២/៣ (ពីរភាគបី)នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងមានសមាជិកយ៉ាងតិចចំនួន ០៥(ប្រាំ)រូប និងមិនលើសពី ១១ (ដប់មួយ)រូបឡើយ ដែលរួមមានប្រធាន ០១រូប ដែលជាអ្នកដឹកនាំសមាគម អនុប្រធាន ០២ រូប អគ្គលេខាធិការ ០១រូប ហេរញ្ញិក ០១រូប និងសមាជិកក្រុមប្រឹក្សាភិបាល ០៦ រូប។

## ប្រការ១៨ ._

**អំពីប្រធានក្រុមប្រឹក្សាភិបាល**

ប្រធានក្រុមប្រឹក្សាភិបាលគឺជាប្រធានសមាគមនិងជាតំណាងស្របច្បាប់របស់សមាគមដែលមានតួនាទី ជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវគ្រប់សកម្មភាពរបស់សមាគម។

## ប្រការ១៩._

**អំពីអនុប្រធានក្រុមប្រឹក្សាភិបាល**

អនុប្រធានក្រុមប្រឹក្សាភិបាល**មានចំនួន ០២រូប** ត្រូវបានកំណត់បែងចែងឲ្យទទួលបន្ទុកអនុវត្ត និងដឹកនាំការងារដូចខាងក្រោមៈ

- ធ្វើជាសេនាធិការឲប្រធានសមាគម
- ធ្វើបំពេញតួនាទីជាប្រធានស្តីទី ក្នុងករណីប្រធានអវត្តមាន ដោយមានការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន
- បំពេញការងារផ្សេងទៀតដែលប្រធានប្រគល់ឲ្យ

## ប្រការ២០ ._

**អំពីអគ្គលេខាធិការ**

អគ្គលេខាធិការ **មានចំនួន ០១រូប** ត្រូវបានកំណត់បែងចែងឲ្យទទួលបន្ទុកអនុវត្ត និងដឹកនាំការងារដូច ខាងក្រោមៈ

- គ្រប់គ្រងការងាររដ្ឋបាល ទ្រព្យសម្បត្តិ សារពើភណ្ឌ
- រៀបចំលិខិតបទដ្ឋាន និងរក្សាតម្កល់ទុកឯកសារ

- គ្រប់គ្រងការងារបុគ្គលិក
- ធ្វើកំណត់ហេតុអង្គប្រជុំនានា និងអង្គសន្និបាត។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ។
- ទទួលអនុវត្តភារកិច្ច និងបំពេញកិច្ចការផ្សេងៗ ទៀត ដែលប្រធានក្រុមប្រឹក្សាភិបាលប្រគល់ឲ្យ។

**ប្រការ២១._**

**អំពីហេរញ្ញិក**

ហេរញ្ញិក **មានចំនួន ០១រូប** ត្រូវបានកំណត់បែងចែងឲ្យទទួលបន្ទុកអនុវត្ត និងដឹកនាំការងារ ដូចខាងក្រោមៈ

- គ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូល ចំណាយរបស់សមាគម
- ធ្វើគម្រោងថវិកាប្រចាំឆ្នាំនិងធ្វើរបាយការណ៍ហិរញ្ញវត្ថុ ជូនប្រធានសមាគមដើម្បីដាក់ជូនទៅក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ទទួលអនុវត្តភារកិច្ច និងបំពេញកិច្ចការផ្សេងៗ ទៀត ដែលប្រធានក្រុមប្រឹក្សាភិបាលប្រគល់ឲ្យ។

**ប្រការ២២._**

**អំពីកិច្ចប្រជុំក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំគ្នា ១ដង ក្នុងមួយខែ តាមការអញ្ជើញរបស់ប្រធានសមាគម និងអាចប្រជុំជាវិសាមញ្ញ បានតាមការស្នើសុំរបស់ប្រធានសមាគម ឬ ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាលឲ្យមានភាពរីកចម្រើន។

**ប្រការ២៣._**

**អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គសន្និបាតទាំងពីរប្រភេទមានតម្លៃគតិយុត្តបាន លុះត្រាតែការអនុម័តនេះ មានសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុងសន្និបាតយ៉ាងហោចណាស់ ២/៣(ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានអង្គសន្និបាតមានឧត្តមានុភាព។ ប្រធានអង្គសន្និបាតអាចជាប្រធានសមាគម ឬបុគ្គលដែលមានឯករាជ្យភាពតាមការជ្រើសរើសរបស់អង្គសន្និបាត។

## ជំពូកទី៥
## ប្រភពធនធាន ទ្រព្យសម្បត្តិ និងការគ្រប់គ្រង

**ប្រការ២៤._**

**អំពីប្រភពធនធាន ទ្រព្យសម្បត្តិ**

**សមាគមសហគ្រិនស្ត្រីកម្ពុជា** មានប្រភពមូលនិធិបានមកពី :

- ភាគទាន ឬវិភាគទាន ឬបរិសទានរបស់សមាជិក និងបុគ្គលិក
- អំណោយជាសម្ភារ ឬថវិកាពីបណ្តាសប្បុរសជននានា
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- ចំណូលបានមកពីសកម្មភាពស្របច្បាប់របស់សមាគម។

**ប្រការ២៥._**

**អំពីការគ្រប់គ្រង**

រាល់ចំណូលទាំងអស់របស់**សមាគមសហគ្រិនស្ត្រីកម្ពុជា**ត្រូវគ្រប់គ្រងដោយហេរញ្ញិករបស់ សមាគមដោយមានការចុះហត្ថលេខាយល់ព្រមពីប្រធានសមាគម។ ចំណូលជាសាច់ប្រាក់ឬមូលប្បទានប័ត្រទាំងអស់ត្រូវបញ្ចូលទៅក្នុងគណនីធនាគារស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់សមាគមទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ ថវិកាអាចរក្សាទុកមួយចំនួននៅក្នុងបេឡារបស់សមាគម សម្រាប់ប្រើប្រាស់ជាការ ចាំបាច់ក្នុងសមាគមតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។ រាល់ការដកសាច់ប្រាក់ឬមូលប្បទានប័ត្រពីធនាគារ គឺត្រូវមានការចុះហត្ថលេខារបស់ហេរញ្ញិក និងប្រធានសមាគម ឬអាចផ្ទេរសិទ្ធិទៅឲ្យរូបវន្តបុគ្គលណាមួយ ដែលជាសមាជិកក្រុមប្រឹក្សាភិបាល តាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ។

ស.អ

## ជំពូកទី ៦
## វិសោធនកម្មលក្ខន្តិកៈ និងការរំលាយសមាគម

**ប្រការ២៦.–**

**អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ**

លក្ខន្តិកៈរបស់ **សមាគមសហគ្រិនស្ត្រីកម្ពុជា** អាចធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាលរបស់សមាគម។ការអនុម័តលើរាល់ការសម្រេចនៃការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សមាគម គឺជាសមត្ថកិច្ចរបស់សន្និបាត។

**ប្រការ២៧.–**

**អំពីការរំលាយសមាគម**

មានតែសន្និបាតតែមួយគត់ដែលអាចសម្រេចរំលាយសមាគមនេះបាន។ នៅពេលសមាគមត្រូវបានរំលាយសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីរបស់សមាគម។ រាល់ទ្រព្យសម្បត្តិរបស់សមាគមដែលនៅសល់ដើម្បីជម្រះបញ្ជីរបស់សមាគម។ រាល់ទ្រព្យសម្បត្តិរបស់សមាគមដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់សមាគមរួចត្រូវចាត់ចែងទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ សមាជិក និងបុគ្គលិកសមាគមទាំងអស់ក៏ត្រូវបានរំសាយផង ដែរនៅពេលដែលសមាគមត្រូវបានរំលាយ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២៨.–**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់ **សមាគមសហគ្រិនស្ត្រីកម្ពុជា** ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះនឹងត្រូវទុកជានិរាករណ៍។

**ប្រការ២៩.–**

**សមាគមសហគ្រិនស្ត្រីកម្ពុជា** ត្រូវធ្វើសកម្មភាពដោយអនុវត្តឲ្យស្របតាមលក្ខន្តិកៈរបស់ខ្លួនដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនិងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ ក្នុងករណីប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈនេះ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចាត់វិធានការតាមនីតិវិធីច្បាប់។

**ប្រការ៣០.–**

លក្ខន្តិកៈរបស់**សមាគមសហគ្រិនស្ត្រីកម្ពុជា** មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៧

**ក្រុមប្រឹក្សាភិបាល**
**ប្រធាន**

**កែវ មុំ**

**បានតម្កល់ទុកលក្ខន្តិកៈ**
របស់
សមាគម សហគ្រិនស្ត្រីកម្ពុជា
ដែលបានធ្វើវិសោធនកម្ម នៅក្រសួងមហាផ្ទៃ តាមលិខិត
លេខ:១៣៩៧...សជណ ចុះថ្ងៃទី១៧ខែ.សីហា.ឆ្នាំ ២០១៧។
រាជធានីភ្នំពេញ. ថ្ងៃទី១៧.ខែ.សីហា...ឆ្នាំ ២០១៧.
**នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ**
**ប្រធាន**

**ឈឹម ការ៉ន**

លក្ខន្តិកៈ ស.អ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ
## រូបសញ្ញា និងត្រា
## សមាគមសហគ្រិនស្ត្រីកម្ពុជា
## CAMBODIA WOMEN ENTREPRENEURS ASSOCIATION

**ក.អំពីរូបសញ្ញា**

CWEA
សមាគមសហគ្រិនស្ត្រីកម្ពុជា
CAMBODIA WOMEN ENTREPRENEURS ASSOCIATION

**ខ.អំពីត្រា**

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៧
**ក្រុមប្រឹក្សាភិបាល**
**ប្រធាន**

**កែវ មុំ**